ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពត**

សំណុំរឿងព្រហ្មទណ្ឌលេខ ៩០៧
ចុះថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០២១
សំណុំរឿងស៊ើបសួរលេខ ៣៥៩
ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ១០៥
ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០២២
សាលក្រមព្រហ្មទណ្ឌលេខ២៦៣-ជ-
ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២២

# សាលក្រមព្រហ្មទណ្ឌ

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពត

បានបើកសវនាការជំនុំជម្រះជា**អសាធារណៈ** នៅសាលាដំបូងខេត្តកំពត ។

កាលបរិច្ឆេទបើកសវនាការ នៅថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២២ វេលាព្រឹក ។

កាលបរិច្ឆេទប្រកាសសាលក្រម នៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២២ វេលាព្រឹក ។

ដែលមានសមាសភាពដូចតទៅ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] ចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

-លោកស្រី [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពត

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពត

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩០៧ ចុះថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០២១ ដែលមាន ៖

<u>**ជនជាប់ចោទ**</u>

១-ឈ្មោះ [redacted] លៀម ភេទស្រី អាយុ៥០ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត [redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពត ឪពុកឈ្មោះ[redacted] សង់ (ស) ម្តាយឈ្មោះ[redacted]អឿន (ស) ប្តីឈ្មោះ [redacted] ហួ (រ) មានកូន០៩នាក់ ជា"នីតិជន" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន (ក្នុងឃុំ)

ជាប់ចោទពីបទ **សញ្ចារកម្ម និងសញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ** ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ ហាក់ ម៉េង ភូមិត្រពាំងខ្សង់ ឃុំអង្គភ្នំតូច ស្រុកអង្គរជ័យ ខេត្តកំពត កាលពីថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០២១ និងនៅ ភូមិត្រពាំងរាំង ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងនិងផ្តន្ទាទោសតាមមាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ។



Scanned with CamScanner

២-ឈ្មោះ [redacted] សុវីរៈ ភេទប្រុស កើតឆ្នាំ១៩៨៩ ជនជាតិខ្មែរ មុខរបរអាជីវករ ទីកន្លែងកំណើត [redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ហេន (រ) ម្តាយឈ្មោះ [redacted]សារី (រ) ប្រពន្ធឈ្មោះ [redacted] ស្រីអូន (រ) មានកូន០២នាក់ ជា"និតិជន" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន (ក្នុងឃុំ)

ជាប់ចោទពីបទ **សញ្ចារកម្ម** ប្រព្រឹត្តនៅ ភូមិត្រពាំងរាំង ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងនិងផ្តន្ទាទោសតាមមាត្រា ២៥ និងមាត្រា ២៦ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

១-លោកមេធាវី [redacted] អត្តលេខ .. និងលោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]លៀម ។

២-លោកមេធាវី [redacted] និងលោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុវីរៈ ។

**ដើមបណ្តឹងរដ្ឋប្បវេណី**

១-ឈ្មោះ [redacted] សារុំ ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីលំនៅបច្ចុប្បន្ននៅ ភូមិក្រសាំង ឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត ។

២-ឈ្មោះ [redacted] យ៉េត ភេទស្រី អាយុ៥២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ ភូមិខ្លាក្រហឹម ឃុំខ្លាក្រហឹម ស្រុកត្រាំកក់ ខេត្តតាកែវ ។

៣-ឈ្មោះ [redacted] សុខផេន ភេទស្រី អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ មានទីលំនៅបច្ចុប្បន្ននៅ ភូមិខ្លាក្រហឹម ឃុំខ្លាក្រហឹម ស្រុកត្រាំកក់ ខេត្តតាកែវ ។

**មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី**

-លោកមេធាវី [redacted] លោកស្រីមេធាវី [redacted] ជាមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

ត្រូវបានបញ្ជូនមកជំនុំជម្រះតាម ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៤៥ ព.ទ/២២ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពត ។

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ

កាលពីថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង០១រសៀល នៅចំណុចផ្ទះសំណាក់ ហាក់ហេង ស្ថិតនៅភូមិត្រពាំងខ្យង ឃុំអង្គភ្នំតូច ស្រុកអង្គរជ័យ ខេត្តកំពត មានករណី សញ្ចារកម្មទាក់ទងពេស្យាចារកុមារ មួយបានកើតឡើង ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] លៀម ភេទស្រី អាយុ៥០ឆ្នាំ ដោយជនសង្ស័យបានធ្វើសកម្មភាពនាំក្មេងស្រីចំនួន០៤នាក់ រួមមាន ១.ឈ្មោះ [redacted] ស្រីគីន ភេទស្រី អាយុ១៥ឆ្នាំ ២.ឈ្មោះ [redacted] ដាលី ភេទស្រី អាយុ១៦ឆ្នាំ ៣.ឈ្មោះ [redacted] លក្ខិណា ភេទស្រី អាយុ១៥ឆ្នាំ ៤.ឈ្មោះ [redacted]នី ភេទស្រី អាយុ១៥ឆ្នាំ យកទៅឱ្យភ្ញៀវនៅផ្ទះ



Scanned with CamScanner

សំណាក់ ហាក់ហេង ដោយក្មេងស្រីបានទទួលសេវា២០០ដុល្លារក្នុងមួយនាក់ ហើយឈ្មោះ [redacted] លៀម យកសេវាពីក្មេងៗក្នុងមួយនាក់៥០ដុល្លារ ។ ក្រោយពីសាកសួរចម្លើយ ឃើញថា ឈ្មោះ [redacted] សុវីរៈ ភេទប្រុស អាយុ៣៤ឆ្នាំ ២.ឈ្មោះ [redacted] លៀម ភេទស្រី អាយុ៥០ឆ្នាំ មានជាប់ពាក់ព័ន្ធករណី សញ្ញារកម្ម កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ នៅចំណុចភូមិត្រពាំងរាំង ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ដោយជនសង្ស័យឈ្មោះ [redacted] សុវីរៈ បានធ្វើសកម្មភាពទាក់ទងមកឈ្មោះ [redacted] លៀម ឱ្យរកនារីពីរនាក់ ដែលមានអាយុ១៨ឆ្នាំ និង១៩ឆ្នាំ ទៅកំដរភ្ញៀវនៅហាងរបស់ខ្លួន ដោយនារីៗនោះ បានទទួលសេវាក្នុងសេវាក្នុងមួយនាក់៦០ម៉ឺនរៀល ហើយថ្លៃសេវានោះ ឈ្មោះ [redacted] សុវីរៈ បានទទួលសេវានោះ ឈ្មោះ [redacted] សុវីរៈ បានទទួលសេវា៤០ម៉ឺនរៀល និងឈ្មោះ [redacted] លៀម បានទទួលសេវា៤០ម៉ឺនរៀល ។ ក្រោយកើតហេតុ សមត្ថកិច្ចក៏បានធ្វើការស៊ើបអង្កេត រហូតឈានដល់ការឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] លៀម និងឈ្មោះ [redacted] សុវីរៈ បញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តកំពត នៅថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០២១ ដើម្បីចាត់ការតាមនីតិវិធី ។

## នាពេលសវនាការ

ក្រោយពីបាន ៖

- សួរនិងស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លៀម និងឈ្មោះ [redacted] សុវីរៈ
- សួរនិងស្តាប់ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីភីន និងឈ្មោះ [redacted] លក្ខិណា
- ស្តាប់អំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ដាលី និងឈ្មោះ [redacted] ដានី
- សួរនិងស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារុំ ឈ្មោះ [redacted] យ៉េត និងឈ្មោះ [redacted] សុខផេន
- សួរនិងស្តាប់ចម្លើយរបស់សាក្សីជាមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] រេវា
- ស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] វិជ្ជនី
- ស្តាប់ក្រឡាបញ្ជីអានរបាយការណ៍ ឯកសារ និងកំណត់ហេតុផ្សេងៗ
- ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
- ស្តាប់តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ
- ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] លៀម និងឈ្មោះ [redacted] សុវីរៈ ។

## សំអាងហេតុ

ក្រោយពីបានពិនិត្យនិងពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់រួចហើយ តុលាការយល់ឃើញថា ៖

១-ជនជាប់ចោទឈ្មោះ [redacted] លៀម និងឈ្មោះ [redacted] សុវីរៈ ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ មជ្ឈិម និងបទ ឧក្រិដ្ឋ ដែលជាបទល្មើសព្រហ្មទណ្ឌមានចែងនិងផ្តន្ទាទោសតាមមាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ចំពោះរឿងនេះ តុលាការត្រូវជំនុំជម្រះនិងសម្រេចរួមជាក្រុម ដោយផ្អែកតាមមាត្រា ២៩១ និងមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

២-សំណុំរឿងនេះមានជនរងគ្រោះជាអនីតិជននិងជានារីភេទ ហើយដំណើរការពិភាក្សាដេញដោលជាសាធារណៈ អាចបណ្តាលឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ។ ដោយហេតុនេះ ក្រុមប្រឹក្សាជំនុំជម្រះសម្រេចការពិភាក្សាដេញដោលជា អសាធារណៈ ទាំងស្រុង ផ្អែកតាមមាត្រា ៣៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-ជនជាប់ចោទឈ្មោះ [redacted] លៀម បានឆ្លើយសារភាពនាពេលសវនាការថា នាងខ្ញុំទទួលស្គាល់ចំពោះបទចោទប្រកាន់របស់តំណាងអយ្យការ ។ ខ្ញុំសុំបញ្ជាក់ជូនថាកាលពីអំឡុងឆ្នាំ២០២១ មានម្តាយជនរងគ្រោះចំនួន០៤នាក់បានមក ពឹងពាក់ខ្ញុំ ដើម្បីឱ្យខ្ញុំជួយរកភ្ញៀវឱ្យកូនគាត់ ដើម្បីឱ្យកូនគាត់ដេកជាមួយភ្ញៀវ ដើម្បីបានលុយដោះស្រាយជីវភាព ព្រោះជីវភាពគាត់មានការខ្វះខាតខ្លាំង ។ ហើយមានថ្ងៃមួយខ្ញុំបានជួបភ្ញៀវម្នាក់ ហើយក៏បានយកលេខ ទូរស័ព្ទគេទុក រួចហើយថ្ងៃមួយក៏មានភ្ញៀវនោះទូរស័ព្ទមកខ្ញុំ ឱ្យជួយរកក្មេងៗចំនួន០៤នាក់ ដោយគាត់បានណាត់ខ្ញុំឱ្យទៅជួបនៅផ្ទះសំណាក់ខាងជើងផ្លូវរទេះភ្លើងតាខ្មៅ ពេលនោះខ្ញុំក៏នាំក្មេងៗចំនួន០៤នាក់ ទៅផ្ទះសំណាក់នោះតាមការណាត់ ។ ពេលទៅដល់បានឃើញភ្ញៀវទូរស័ព្ទមកខ្ញុំនោះ គាត់ក៏ចេញមកសួរខ្ញុំថាក្មេងៗមកគ្រប់អស់នៅ ខ្ញុំក៏ឆ្លើយថាគ្រប់អស់ហើយនៅក្នុងបន្ទប់ ពេលនោះគាត់ថាគាត់ទៅហៅគ្នាគាត់មកពីរនាក់ទៀត បន្តិចក្រោយមកក៏ឃើញមានសមត្ថកិច្ច ចុះមកឃាត់ខ្លួនពួកខ្ញុំតែម្តង។ សុំបញ្ជាក់បន្ថែមថាកន្លងមកខ្ញុំក៏ធ្លាប់មានម្តាយក្មេងៗចំនួន០២នាក់ ធ្លាប់ពឹងខ្ញុំឱ្យរកភ្ញៀវឱ្យកូនគាត់ដែរ ហើយខ្ញុំបានទាក់ទងទៅឈ្មោះ [redacted] វីរៈ ថាមានភ្ញៀវណាចង់រកនារីអង្គុយលេងដែររឺអត់? ក្រោយមកខ្ញុំក៏បានឱ្យក្មេងៗពីរនាក់នោះ ទៅហាងរបស់ឈ្មោះ [redacted] វីរៈ តែម្តង តែខ្ញុំមិនបានដឹងថាក្មេងៗនោះ បានទៅដេកជាមួយភ្ញៀវ ឬអត់នោះទេ ។ នៅល្ងាចថ្ងៃ ដដែលម្តាយក្មេងៗនោះ បានយកលុយមកឱ្យខ្ញុំចំនួន៤០ម៉ឺនរៀល លុះពេលបានលុយនេះ ខ្ញុំក៏បានវេលុយឱ្យ ឈ្មោះ [redacted] វីរៈ ចំនួន២០ម៉ឺនរៀល តាមរយៈវីង។ មុនពេលខ្ញុំនាំក្មេងៗទៅ ខ្ញុំក៏បានប្រាប់ថាទៅដេកជាមួយភ្ញៀវដែរ ហើយពួកគេសុទ្ធតែស្ម័គ្រចិត្ត គ្មានអ្នកណាបង្ខំនោះទេ ហើយពួកគេសុទ្ធតែប្រាប់ខ្ញុំអាយុពី១៧ទៅ១៨ឆ្នាំអស់ហើយ ទើបនាងខ្ញុំហ៊ាន ។ ចំពោះឈ្មោះ [redacted] វីរៈ ទើបតែទូរស័ព្ទរកក្មេងៗឱ្យអង្គុយ លេងជាមួយភ្ញៀវម្តងនេះទេ គឺឱ្យរកក្មេងៗពីរនាក់ ។ ចំពោះថ្ងៃដែលសមត្ថកិច្ចចុះឃាត់ខ្លួនខ្ញុំពេលយកក្មេងៗ ចំនួន០៤នាក់ ទៅផ្ទះសំណាក់នោះ ខ្ញុំពុំបានដឹកពួកគេទៅទេ គឺក្មេងម្នាក់ជាអ្នកឌុបខ្ញុំទៅជាមួយគេ ហើយ០៣នាក់ទៀតគេជិះម៉ូតូទៅខ្លួនឯង ។

៤-ជនជាប់ចោទឈ្មោះ [redacted] សុវីរៈ បានឆ្លើយបដិសេធនូវការចោទប្រកាន់នាពេលសវនាការថា ខ្ញុំសុំបដិសេធចំពោះការចោទប្រកាន់របស់តំណាងអយ្យការដែលចោទប្រកាន់ខ្ញុំថា បានប្រព្រឹត្តអំពើសញ្ញារកម្មនោះទាំងស្រុង ។ ខ្ញុំទើបតែស្គាល់ឈ្មោះ [redacted] លៀម ទេ គឺស្គាល់តាមរយៈភ្ញៀវមកហូបអីនៅហាងរបស់ខ្ញុំ ហើយគាត់បានឱ្យលេខទូរស័ព្ទរបស់ឈ្មោះ [redacted] លៀម មកខ្ញុំ។ លុះមកដល់អំឡុងខែវិច្ឆិកា ឆ្នាំ២០២១ មានភ្ញៀវមកហូបអីនៅហាងខ្ញុំ ចំនួន០៤នាក់ជាប្រុសៗ រួចក៏បានសួរខ្ញុំរកក្មេងៗ ដើម្បីឱ្យមកអង្គុយកំដរចាក់ស្រា ពេលនោះខ្ញុំក៏បានទូរស័ព្ទទាក់ទងទៅឈ្មោះ [redacted] លៀម ដើម្បីឱ្យជួយទាក់ទងរកក្មេងៗឱ្យ ហើយឈ្មោះ [redacted] លៀម បានប្រាប់ថាចាំបន្តិច ហើយបន្តិចក្រោយមកខ្ញុំក៏បានឃើញក្មេងស្រីៗចំនួន០២នាក់ ជិះម៉ូតូមកដល់ហាងរបស់ខ្ញុំ ហើយពួកគេក៏បានចូលទៅហូបអីជាមួយភ្ញៀវ ដោយខ្ញុំពុំបាននិយាយអ្វីទេ ។ ពេលភ្ញៀវហូបអីដល់ម៉ោងប្រហែល០៣រសៀល ភ្ញៀវក៏ជិះឡានចេញទៅវិញបាត់ ហើយក្មេងៗនោះក៏បានជិះម៉ូតូទៅវិញបាត់ដែរ ខ្ញុំពុំបានដឹងរឿងអ្វីទៀតនោះទេ ហើយក៏មិនដឹងថាក្មេងៗនោះទៅជាមួយភ្ញៀវនោះឬអត់នោះទេ ។ លុះដល់ល្ងាចថ្ងៃដដែលខ្ញុំបានទទួលលុយចំនួន២០ម៉ឺនរៀល ដោយឈ្មោះ [redacted]



Scanned with CamScanner

លៀម ជាអ្នកវេរមកឱ្យខ្ញុំ ហើយគាត់ប្រាប់ថាម្ដាយក្មេងៗឱ្យជាសគុណដែលឱ្យកូនគាត់មកធ្វើការ នៅហាងរបស់ខ្ញុំ ខ្ញុំក៏ទទួលយកតែមិនដឹងថាលុយនោះបានមកពីណាទេ ។ កន្លងមកខ្ញុំមិនដែលនាំក្មេងៗមក ឱ្យអង្គុយកំដរភ្ញៀវដូច្នេះនោះទេ ទើបតែលើកទី១ប៉ុណ្ណោះ ។

៥-តាមរយៈការពិនិត្យចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លៀម ខាងលើនេះ គឺមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនរងគ្រោះ និងចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីដែលបានឆ្លើយបញ្ជាក់ជូនតុលាការផងដែរ ។ ជនរងគ្រោះឈ្មោះ [redacted] ស្រីភីន បានឆ្លើយនាពេលសវនាការថា នៅថ្ងៃកើតហេតុនោះអ៊ុំ លៀម នាំខ្ញុំទៅដេករួមភេទជាមួយភ្ញៀវនៅផ្ទះសំណាក់ ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបានតែម្ដង ។ ដោយថ្ងៃនោះខ្ញុំយល់ព្រមទៅដោយខ្លួនឯង ដោយអ៊ុំ លៀម បានប្រាប់ថាទៅដេកជាមួយភ្ញៀវគេឱ្យតម្លៃ៨០ម៉ឺនរៀល គេយក ៤០ម៉ឺនរៀល នៅសល់៤០ម៉ឺនរៀល ហើយខ្ញុំសន្យាថាឱ្យមកអ៊ុំ លៀម ចំនួន២០ម៉ឺនរៀល ប៉ុន្តែថ្ងៃនោះ ពុំទាន់ បានដេកជាមួយភ្ញៀវផងក៏ត្រូវសមត្ថកិច្ចចាប់បានតែម្ដង ។ ពេលមកផ្ទះសំណាក់ខ្ញុំមានគ្នា០៤នាក់ ។ កន្លងមក ខ្ញុំធ្លាប់មកដេកជាមួយភ្ញៀវតាមរយៈអ៊ុំ លៀម ម្ដងរួចមកហើយ ដោយភ្ញៀវជាអ្នកឱ្យលុយមកខ្ញុំផ្ទាល់បានលុយ ចំនួន២០ម៉ឺនរៀល ហើយពេលនិយាយតម្លៃជាមួយភ្ញៀវគឺអ៊ុំ លៀម ជាអ្នកនិយាយតម្លៃជាមួយភ្ញៀវ ។ ពីមុនមកខ្ញុំធ្លាប់រួមភេទជាមួយភ្ញៀវដែរ ដោយទៅជាមួយមិត្តភក្តិ ពេលបានលុយមកខ្ញុំយកមកចាយទិញខោអាវ ។ ខ្ញុំធ្លាប់រួមភេទជាមួយសង្សា តាំងពីមុនខ្ញុំដេកជាមួយភ្ញៀវមកម្ល៉េះ ។ ពេលខ្ញុំដេកជាមួយភ្ញៀវគេឱ្យលុយមកខ្ញុំ ខ្ញុំបានឱ្យលុយនោះពាក់កណ្ដាលទៅឱ្យអ៊ុំ លៀម ។ ហើយជនរងគ្រោះឈ្មោះ [redacted] លក្ខិណា បានឆ្លើយផងដែរថា ថ្ងៃនោះខ្ញុំទៅផ្ទះសំណាក់ហាក់ហេងជាមួយគាត់ ដោយគាត់ប្រាប់នាងខ្ញុំថាទៅជួបភ្ញៀវ ហើយខ្ញុំក៏ដឹងថាទៅជាមួយភ្ញៀវនោះ ដើម្បីរួមភេទដែរ ដោយគាត់ប្រាប់ថាទៅបានលុយ២០ម៉ឺនរៀល ។ កន្លងមកខ្ញុំធ្លាប់រួមភេទជាមួយសង្សា តាំងពីមុនពេលខ្ញុំដេកជាមួយភ្ញៀវមកម្ល៉េះ។ មុនពេលថ្ងៃសមត្ថកិច្ចចាប់ខ្លួនខ្ញុំ ខ្ញុំធ្លាប់ដេកជាមួយភ្ញៀវម្ដងដែរ គឺតាមរយៈអ៊ុំ លៀម ដែរ នៅផ្ទះសំណាក់ដដែល។ នៅពេលទៅដេកជាមួយភ្ញៀវនោះ ខ្ញុំស្ម័គ្រចិត្តទៅដោយខ្លួនឯង គ្មានអ្នកណាបង្ខំខ្ញុំនោះទេ ។

៦-ចម្លើយរបស់ជនរងគ្រោះ គឺមានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] អោវ ជាមន្ត្រីនគរបាលយុត្តិធម៌ដែលបានចុះប្រតិបត្តិការករណីនេះ នាពេលសវនាការថា កន្លងមកមានប្រជាពលរដ្ឋ ប្ដឹងទៅខាងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ថាមានករណី ជួញដូរផ្លូវភេទ នៅក្នុងភូមិសាស្ត្រស្រុកអង្គរជ័យ ខេត្តកំពត ពេលបានដំណឹងដូច្នេះ កម្លាំងយើងខ្ញុំក៏បានដាក់កម្លាំងតាមដានស៊ើបអង្កេតស្រាវជ្រាវ ពេលនោះកម្លាំងយើងក៏បានស៊ើបដឹងថា ពិតជាមានករណីជួញដូរកុមារដូច្នេះ ពិតប្រាកដមែន។ ក្រោយមកក្រុមការងារក៏បានរាយការណ៍មកជូន ឯកឧត្តមព្រះរាជអាជ្ញា ដើម្បីសុំគោលការណ៍ចុះបង្ក្រាប និងចុះឃាត់ខ្លួនបានជនសង្ស័យចំនួន០២នាក់ ភ្លាមៗនៅកន្លែងកើតហេតុ។ ក្រោយមកក៏បានកសាងសំណុំរឿងបញ្ជូនមកតុលាការតែម្ដង។

៧-មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី បានធ្វើសេចក្ដីសន្និដ្ឋានថា ជនជាប់ចោទទាំងពីរនាក់ សុទ្ធតែបានទទួលស្គាល់ថាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន ដូច្នេះស្នើសុំតុលាការផ្ដន្ទាទោសក្នុងកម្រិតអតិបរមា ព្រោះជនរងគ្រោះទើបតែមានអាយុ១៥ឆ្នាំ ប៉ុណ្ណោះ ។ ហើយតំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា តំណាងអយ្យការសូមរក្សាបទចោទលើជនជាប់ចោទ ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរ និង ស្នើសុំតុលាការផ្ដន្ទាទោសជនជាប់



Scanned with CamScanner

ចោទទៅតាមផ្លូវច្បាប់ ។

៨-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លៀម បានធ្វើសេចក្តីសន្និដ្ឋានថា ដោយសារមានការ ពឹងពាក់ពីម្តាយជនរងគ្រោះ និងមានការស្ម័គ្រចិត្តពីជនរងគ្រោះ ហើយកូនក្តីខ្ញុំជាមនុស្ស ស្លោះត្រង់ និងពុំបានរៀនសូត្រផង ទើបប្រព្រឹត្តដូច្នេះតែម្តង ។ ពេលនេះស្នើសុំលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំផង ។ ហើយមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុវីរៈ បានធ្វើសេចក្តីសន្និដ្ឋានថា តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] លៀម និងចម្លើយជនរងគ្រោះ ព្រមទាំងចម្លើយសាក្សី ឃើញថា ពុំមានជាប់ពាក់ព័ន្ធដល់កូនក្តីខ្ញុំនោះទេ ហើយកូនក្តីខ្ញុំក៏បានឆ្លើយបដិសេធហើយដែរ ។ ដូច្នេះស្នើសុំតុលាការមេត្តាលើកលែងការចោទប្រកាន់ ដល់កូនក្តីខ្ញុំបាទ និងដោះលែងឱ្យនៅក្រៅឃុំបានទៅជួបជុំគ្រួសារវិញផង ។

៩-ផ្អែកតាមចម្លើយរបស់ជនពាក់ព័ន្ធខាងលើ និងភស្តុតាងក្នុងសំណុំរឿង ព្រមទាំងតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] លៀម នោះ ឃើញថា កាលពីកាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] លៀម ពិតជាបាននាំជនរងគ្រោះចំនួន០២នាក់ ទៅភូមិត្រពាំងវាំង ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ដើម្បីប្រព្រឹត្តអំពើពេស្យាចារ និងក្រោយមកបាននាំជនរងគ្រោះជាអនីតិជនចំនួន០៤នាក់ ទៅរួមភេទនៅផ្ទះសំណាក់ហាក់ហេង ស្ថិតក្នុងភូមិត្រពាំងខ្យង ឃុំអង្គភ្នំតូច ស្រុកអង្គរជ័យ ខេត្តកំពត និង ដើម្បីទទួលបានប្រាក់ពីអំពើពេស្យាចារពិតមែន ។ ហើយផ្អែកតាមចម្លើយរបស់ជនពាក់ព័ន្ធខាងលើ និងភស្តុតាងក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុវីរៈ គឺពិតជាបានជួយសម្រួលដល់ការប្រព្រឹត្តអំពើពេស្យាចាររបស់ជនជាប់ចោទឈ្មោះ [redacted] លៀម ផងដែរ ។ ចំពោះអំពើរបស់ជនជាប់ចោទទាំងពីររូបនេះ គឺពិតជាកើតចេញពីចេតនាទុច្ចរិតយ៉ាងពិតប្រាកដ ដោយហេតុថា ជនជាប់ចោទគឺបានដឹងរួចទៅហើយថា អំពើរបស់ខ្លួនជាអំពើខុសច្បាប់ ប៉ុន្តែជនជាប់ចោទនៅតែប្រព្រឹត្ត ហើយបានទាញយកប្រយោជន៍ពីជនរងគ្រោះទៀតផង ។

១០-យោងតាមមាត្រា ២៥ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចែងថា "*អំពើសញ្ចារកម្ម នៅក្នុងច្បាប់នេះ មានន័យថា ១.ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ ២.ជួយ ឬ ការពារអំពើពេស្យាចាររបស់ជនដទៃ ៣.ជ្រើសរើស អូសទាញ ឬ បណ្តុះបណ្តាលបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ ៤.ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ ។*" ហើយតាមមាត្រា ២៦ នៃច្បាប់ដដែលនេះបានកំណត់អំពីទោសថា "*ជនណាដែលប្រព្រឹត្តសញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ដល់ ៥ឆ្នាំ ។*" ហើយតាមមាត្រា ២៨ នៃច្បាប់ដដែលនេះ បានកំណត់ផងដែរថា "*សញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ដល់១៥ឆ្នាំ កាលបើបុគ្គលដែលធ្វើពេស្យាចារនោះ ជាអនីតិជន ។ ពាក្យថា ពេស្យាចារ នៅក្នុងបទប្បញ្ញត្តិពាក់ព័ន្ធនានានៃជំពូកនេះ ត្រូវជំនួសដោយពាក្យ ពេស្យាចារកុមារ នៅពេលដែលបទល្មើសដែលមានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះត្រូវអនុវត្ត ។*"

១១-ដោយផ្អែកតាមមូលហេតុនិងសំអាងហេតុខាងលើនេះ គឺពិតជាមានបន្ទុកនិងធាតុផ្សំគ្រប់គ្រាន់ ដែលអាចឱ្យតុលាការកំណត់និងប្រកាសបានថា ពិតជាមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] លៀម ពីបទ សញ្ចារកម្ម និងសញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ ហាក់ហេង ភូមិត្រពាំងខ្យង ឃុំអង្គភ្នំតូច



Scanned with CamScanner

ស្រុកអង្គរជ័យ ខេត្តកំពត កាលពីថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០២១ និងនៅ ភូមិត្រពាំងរាំង ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងនិងផ្តន្ទាទោស តាមមាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ និងពិតជាមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សុវីរៈ ពីបទ **សមគំនិតក្នុងអំពើសញ្ញារកម្ម** ប្រព្រឹត្តនៅ ភូមិត្រពាំងរាំង ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងនិងផ្តន្ទាទោសតាមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ មាត្រា ២៥ និងមាត្រា ២៦ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

១២-ជនជាប់ចោទឈ្មោះ [redacted] លៀម បានឆ្លើយសារភាពតាំងពីដំណាក់កាលនគរបាលយុត្តិធម៌ រហូតដល់ការជំនុំជម្រះ ហើយក្នុងរឿងនេះ ពុំមានជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងទាមទារសំណងទៅលើជនជាប់ចោទនោះឡើយ ។ ដោយហេតុ គប្បីតុលាការផ្តន្ទាទោសជនជាប់ចោទឱ្យបានសមស្រប តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ និងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ។ ចំណែកឯជនជាប់ចោទឈ្មោះ [redacted] សុវីរៈ ទោះបីជាបានប្រព្រឹត្តបទល្មើស ប៉ុន្តែជនជាប់ចោទពុំបានបង្ករឱ្យមានព្យសនកម្មធ្ងន់ធ្ងរទៅលើជនរងគ្រោះនោះឡើយ ហើយជនរងគ្រោះក៏ពុំមែនជាអនីតិជនផងដែរ ព្រមទាំងមិនបានប្តឹងទៅលើជនជាប់ចោទផងដែរ ។ ម្យ៉ាងទៀត ដោយជនជាប់ចោទទើបប្រព្រឹត្តបទល្មើសជាលើកដំបូងផងនោះ គប្បីតុលាការផ្តន្ទាទោស ទៅតាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ និងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ និងអនុវត្តនូវការព្យួរទោសធម្មតាមួយផ្នែក ដោយយោងតាមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

១៣-ក្នុងរឿងនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយនៅចំពោះចៅក្រមស៊ើបសួរ និងនាពេលសវនាការរួចហើយថាពុំប្តឹងទាមទារសំណងរដ្ឋប្បវេណីពីជនជាប់ចោទនោះឡើយ ។ ដោយហេតុនេះ តុលាការនឹងមិនពិចារណាសម្រេចអ្វីអំពីសំណងរដ្ឋប្បវេណីទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។

១៤-នៅក្នុងរឿងនេះ ជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី បានចូលរួមសវនាការ ប៉ុន្តែមិនបានចូលរួមស្តាប់ការប្រកាសសាលក្រមនោះឡើយ ។ ដោយហេតុនេះ គប្បីតុលាការប្រកាសសាលក្រមនេះ ចាត់ទុកចំពោះមុខជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកតាមមាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ដូចមានកំណត់ក្នុងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## សេចក្តីសម្រេច

## ហេតុដូច្នេះ សាលាដំបូងខេត្តកំពត សម្រេច

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លៀម ជានីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន០៧(ប្រាំពីរ)ឆ្នាំ ពីបទ សញ្ញារកម្ម និងសញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ហាក់ហេង ភូមិត្រពាំងខ្យង ឃុំអង្គភ្នំតូច ស្រុកអង្គរជ័យ ខេត្តកំពត កាលពីថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០២១ និងនៅ ភូមិត្រពាំងរាំង ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងនិងផ្តន្ទាទោសតាមមាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ។



Scanned with CamScanner

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុវីរៈ ជានីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន០២(ពីរ)ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារចំនួន០៦(ប្រាំមួយ)ខែ ទោសនៅសល់ពីនេះត្រូវព្យួរទោសធម្មតា ពីបទ សមគំនិតក្នុងអំពើសញ្ញារកម្ម ប្រព្រឹត្តនៅ ភូមិត្រពាំងរាំង ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងនិងផ្តន្ទាទោសតាមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥ និងមាត្រា ២៦ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

-សំណុំរឿងព្រហ្មទណ្ឌនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២២ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២២ ចាត់ទុកចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លៀម និងឈ្មោះ [redacted] សុវីរៈ និងចាត់ទុកចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារុំ ឈ្មោះ [redacted] យ៉េត និងឈ្មោះ [redacted] សុខផេន ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥

ធ្វើនៅ កំពត, ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រម

[redacted]